HONEYCOMB 2/3 (July 2001): 1–7



# How Can They Believe? How Can They Hear? The Khmer Church in Cambodia Today

*Alice COMPAIN*

## Background

The name of Christ was probably first brought to Cambodia by Portuguese and Spanish traders in the sixteenth century. The stormy passage of the Roman Catholic Church in Cambodia has been well recorded in François Ponchaud's *Cathedral of the Rice Paddy*.[1] It seems that only Brahmanism and Buddhism came across from India at the beginning of the Christian era when cultural links were growing between India and Cambodia, even though we know that a church existed in southern India from the first century. But the Khmer people—apart from those living in Siam where the gospel first penetrated in the early nineteenth century—had to wait until the twentieth century to hear the evangelical gospel.

---

[1]François Ponchaud, *The Cathedral of the Rice Paddy—450 Years of History of the Church in Cambodia*, preface by Bishop Yves Ramousse, postface by Cardinal Etchegaray, translated by Nancy Pignarre and the Bishop Salas Cambodian Catholic Center (Le Sarment: Librairie Arthème Fayard, 1990).

Hudson Taylor, founder of the China Inland Mission, issued a call to prayer in 1875 for the "vassal" states to the south of China, including Cambodia. Trading links had been established about a thousand years earlier as Chinese settlers came down into the Indochinese peninsula, but China itself was then only just opening up to receive the gospel. Around the world people were praying for Indochina. In 1902 the Swiss Brethren were the first to arrive, settling in southern Laos. God laid the burden of planting the church on the Christian and Missionary Alliance, who sent their first workers to Vietnam in 1911. These pioneers started to preach to the Kampuchea Kraom people in the Mekong Delta, but found the door to Cambodia itself closed to them by the French, who did not want competition for the Catholics. Eventually, however, God gave the Alliance the opportunity to send two missionary families in 1923, the beginning of today's evangelical church in our country.

The early work centered on Battambang, where groups of migrants from Kampuchea Kraom proved responsive. The first known church group was in Chkaè Kôn, where Granny Yim still lives; she came as a five-year-old to live and share Christ in Cambodia with her parents.

Now in the next century where is the church? A simple answer—everywhere! For the first time we can find Christian groups in every province around the country. When you consider the turbulent history of this country, it is amazing to see how God worked so that people can and do believe in Christ. Only twenty years ago there was a deliberate attempt to stamp out not only Christianity (regarded as Western and imperialist) but all religions. Yet God preserved a *remnant*—a significant word applying to those who clung to their faith in spite of everything. Isaiah 46:3–4 reads, "Listen to me . . . all you who remain [i.e., the remnant] of the house of Israel. . . . Even to your old age and gray hairs I am he, I am He who will sustain you. I have made you and I will carry you; . . . I will rescue you."

## Leadership

In 1974 there were only twelve full-time pastors, though many had been trained at the Takhmau Bible School. The entire class I taught there from 1974–75 perished during the Khmer Rouge period, apart from Nhem Sokhun, who died not long after reaching the United States. Yet as I look around today, I see quite a few church leaders who were Christians before 1975, truly preserved by God's grace. Nevertheless, most people in leadership today became Christians after 1990. This is true of virtually all lay pastors in the country churches. They therefore have few models to follow, a fact that shows up in the way they organize their churches like associations or societies with elected committees. Few groups have leaders appointed because of their spiritual qualifications according to the Pauline pattern.

## Training of Leadership

As churches started multiplying, the cry went up, "We need leadership training!" Many Christian mission groups have responded to this call, with the result that seminars, short-term Bible schools, and training sessions are on the calendar virtually every month. The Theological Education by Extension program started by the Christian and Missionary Alliance is currently training over six hundred people, mostly in the provinces. The materials originally written for church leaders in South America are well translated and eminently suitable for the Khmer leaders. A TEE association has been set up to make this training available to the whole church here in Cambodia. Another TEE type program has been started by the Assemblies of God, called "Train and Multiply." This relies on personal mentoring of leaders, who in turn mentor others—good news indeed!

Residential courses are run at seven Baptist centers across the country for two weeks at a time. After two years the rural leaders will have studied for eight sessions, giving them basic training in leading churches and teaching the Bible. The Phnom Penh Bible School has already graduated six classes of students

who have studied for three years, and current enrollment is sixty. Campus Crusade for Christ runs a school for evangelists, and the Assemblies of God opened their Cambodia Bible Institute in July 1996. Kampuchea for Christ also has residential training courses, as do the Methodists. Many short-term courses are also held in Phnom Penh and the provinces, which church leaders from around the country attend.

Training materials are available from many sources, besides the workbooks that go with the above TEE and Bible School courses. Leroy Eims' *How to Be a Leader* was translated from Thai and typed in 1992. There is a range of Christian and evangelistic books that need to be made more readily available to the local churches so that Christians can read for themselves, but few people have access to these books or can afford to buy them. Few, too, have shortwave radios, another great source of teaching through daily FEBC broadcasts, though those living close to FM stations have a choice of Christian programs. Cassettes can be listened to several times over on tape recorders, and some are distributing teaching material this way. But a lot more use could be made of resources already prepared if libraries were set up in each Christian center.

## Evangelism

Most Cambodian Christians have come to believe through the witness of family or close friends. Not only did they hear message of the gospel from them, they also saw how its power changes lives. Sometimes their overseas relatives, converted in the refugee camps or in a third country, have come back and explained the gospel to them.

But in some cases the warm generosity of overseas Christians has clouded the issue and led the poorer relatives to think that becoming a Christian is part of a bargain for receiving assistance. New believers are frequently asked how much they are paid for becoming Christians, and it is not easy for them to give an appropriate answer to dispel these wrong ideas.

Some have become Christians because God healed them. Disease is very prevalent, and the practice of going to folk healers (*krou Khmer*) still very popular. In this context, God has stepped in and shown his power to heal both people's physical bodies and their broken and emotionally distressed hearts, as well as to deliver the many who have allowed the devil to trouble or possess them. Those healed then proclaim the message of God's peace that passes all understanding, unknown to them before accepting Christ.

The most powerful form of evangelism is still the life transformed by the power of Christ. In rural communities no one can hide himself away, and it soon becomes the talk of the village when a person's life is radically changed. Recently I spoke with a former soldier in Svai Reang province who was convinced he had become HIV-positive because of his previous loose lifestyle, and had spent hundreds of dollars seeking treatment. He was attracted to the gospel because of the "trust in Christ" attitude of some fellow villagers. Now he is following Christ—one truly snatched from the fire (Jude 23).

## Worship

Nearly every Sunday there is a new group of Christians meeting somewhere in Cambodia for the first time to worship the true and living God. Every year many hundreds celebrate their first Easter and Christmas. God's church continues to grow numerically, but it still has to mature to attain the whole measure of fullness that Christ has prepared for his body. His aim is to bring church into the unity of the Spirit. Year by year we are seeing a movement in the right direction, towards acknowledging the headship of Christ. Sadly there are still those who seek to get their own groups or denominations established without encouraging fellowship and mutual building up of all the Christians in one given area. But in time local Christians will insist on the truth that they are "the whole body, joined and held together by every supporting ligament, grow[ing] and build[ing] itself in love, as each part does its work (Ephesians 4:16)."

This is already true in the experience of worship, where the Cambodian Christians have their own hymnology and sing with great gusto the indigenous songs given to them by the Lord. How precious this gift of music and poetry and art forms, a heritage of the Khmer people, and now used expressly to worship God! An official in the department of religion and culture in Kampong Thom province recently praised the local churches for upholding Khmer culture in their worship songs.

## Future Development

Having watched the blossoming of churches over the last ten years, I expect growth to continue as more villages are reached with the gospel. Today many people who previously had resisted the gospel message are becoming Christians, just as in the early days of missionary activity so few responded even though many heard. We need to continue to reach out to those who never have had the opportunity to respond to the gospel.

As Christians mature, they should develop a burden to carry the gospel to other districts in their own provinces and beyond. Increasing maturity will also bring a sense of responsibility to "parent" and discipline new Christians. At present many new believers are left to fend for themselves with inadequate follow-up. I would dare to hope that the churches will develop truly into Christian communities caring for one another like their own family and welcoming in the new believers as part of this family.

At present many churches and denominations are heavily dependent on foreign input and NGO's. Therefore they do not fully perceive their own responsibility to carry out Christ's commands in sharing what God has given them. Foreigners need to evaluate whether their input is actually strengthening the new believers' faith in God who "will provide," as we can actually hinder rather than help their trust in God by becoming substitute patrons.

As Christians develop, they will know God on an ever deeper level, and come to acknowledge him as the center of their lives, their families, and their churches. Today we have a

multiplicity of church groups often competing with each other (like shops setting up together to attract customers). When God becomes the focal center, then differences will recede and Christians will willingly join together for fellowship, also to make an impact on the 99.5% of Cambodia that still does not acknowledge Christ as savior.

"Glory to God in the highest, and on earth peace to men on whom His favor rests" (Luke 2:14).



# តើគេអាចជឿយ៉ាងដូចម្តេចបាន? តើគេអាចស្តាប់ឮយ៉ាងដូចម្តេចបាន? ក្រុមជំនុំខ្មែរនៅក្នុងស្រុកខ្មែរសព្វថ្ងៃនេះ

អាលិស កុំប៉ាំង

## សាទុតា

ព្រះនាមព្រះគ្រីស្តប្រហែលជាត្រូវបានគេនាំមកជាដំបូង ចូលមកក្នុងស្រុកខ្មែរ ដោយសារពួកឈ្មួញជនជាតិព័រទុយហ្គេ និង អេស្ប៉ាញកាលពីសតវត្សរ៍ទី១៦ ។ ការចូលមកដ៏ប្រកបដោយកម្លាំងខ្លាំងក្លារបស់ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសខ្មែរ គឺមានកត់ត្រាទុកយ៉ាងច្បាស់នៅក្នុងសៀវភៅមួយឈ្មោះ **Cathedral of the Rice Paddy** [1] របស់លោកឪពុក ហ្វ្រង់ស្វ័រ ប៉ុងសូ ។ គឺហាក់បីដូចជាមានតែលទ្ធិព្រហ្មញ្ញ និង ពុទ្ធសាសនាតែប៉ុណ្ណោះ ដែលបានមកពីប្រទេសឥណ្ឌានៅពេលចាប់ផ្តើមយុគសម័យគ្រីស្តបរិស័ទ នៅពេលដែលមានការទាក់ទងគ្នាខាងផ្នែកវប្បធម៌ រវាងប្រទេសកម្ពុជានិងប្រទេសឥណ្ឌាកាន់តែរីកចំរើនឡើង ទោះបី

---

[1] François Ponchaud, *The Cathedral of the Rice Paddy—450 Years of History of the Church in Cambodia*, preface by Bishop Yvers Ramousse, postface by Cardinal Etchegaray, translated by Nancy Pignarre and the Bishop Salas Cambodian Catholic Center (Le Sarment: Librairie Arthème Fayard, 1990).

ជាយើងដឹងថា មានក្រុមជំនុំកើតឡើង នៅក្នុងភូមិភាគខាងត្បូងនៃប្រទេសឥណ្ឌា កាលពីសតវត្សរ៍ទី១ក៏ដោយ ។ ប៉ុន្តែជនជាតិខ្មែរត្រូវរង់ចាំរហូតដល់សតវត្សរ៍ទី២០ ទើបបានឮការផ្សាយដំណឹងល្អ ក្រៅពីជនជាតិខ្មែរ ដែលរស់នៅក្នុងប្រទេសសៀម ដែលដំណឹងល្អបានជ្រៀតចូលនៅដើមសតវត្សរ៍ទី១៩នោះ ។

លោកហាត់ស៊ុន ថៃល័រ ដែលជាស្ថាបនិកបេសកកម្មនៅក្នុងប្រទេសចិនដីគោក បានចេញការប្រកាសឲ្យអធិស្ឋាននៅក្នុងឆ្នាំ ១៨៧៥ ដើម្បីសុំឲ្យមាន "អ្នកព្រមធ្វើតាម" ដែលបានបញ្ជាក់យ៉ាងច្បាស់ចំពោះប្រទេសចិនភាគខាងត្បូង គិតបញ្ចូលទាំងប្រទេសកម្ពុជាផង ។ ការទាក់ទងគ្នាផ្នែកមុខជំនួញបានបង្កើតឡើងប្រហែលមួយពាន់ឆ្នាំមុនពេលដែលអ្នកតាំងទីលំនៅជនជាតិចិនបានចុះមកកាន់ជ្រោយឥណ្ឌូចិន ប៉ុន្តែប្រទេសចិនខ្លួនឯង នៅពេលនោះទើបតែបើកទទួលដំណឹងល្អ ។ មនុស្សនៅទូទាំងពិភពលោក បានអធិស្ឋានសម្រាប់ឥណ្ឌូចិន ។ នៅក្នុងឆ្នាំ ១៩០២ ក្រុម **Swiss Brethren** គឺជាអ្នកមកដល់មុនគេ ដែលមកតាំងទីលំនៅក្នុងភូមិភាគខាងត្បូងនៃប្រទេសលាវ ។ ព្រះជាម្ចាស់បានដាក់បន្ទុកនៃការបង្កើតក្រុមជំនុំ ចំពោះសម្ព័ន្ធបេសកកម្មសាសនទូតគ្រីស្ទបរិស័ទដំណឹងល្អ (C & MA) ដែលបានបញ្ជូនបុគ្គលិករបស់ខ្លួន ជាដំបូងទៅកាន់ប្រទេសវៀតណាម នៅក្នុងឆ្នាំ១៩១១ ។ ពួកអ្នកត្រួសត្រាយផ្លូវទាំងអស់នេះចាប់ផ្ដើមផ្សាយដំណឹងល្អដល់ប្រជាជននៅកម្ពុជាក្រោម នៅតាមតំបន់ដីសណ្ដទន្លេមេគង្គ ប៉ុន្តែគេបានឃើញថាទ្វារចូលមកក្នុងប្រទេសកម្ពុជាត្រូវបិទជិត ដោយសារពួកបារាំងមិនចង់ឲ្យមានការប្រណាំងប្រជែងគ្នាជាមួយព្រះសហគមន៍កាតូលិក ។ទោះបីជាយ៉ាងណាក៏ដោយព្រះជាម្ចាស់បាន ផ្ដល់ឱកាសឲ្យនិកាយសម្ព័ន្ធបេសកកម្មសាសនទូតគ្រីស្ទបរិស័ទដំណឹងល្អ (C & MA) បញ្ជូនបេសកជនពីរគ្រួសារនៅក្នុងឆ្នាំ ១៩២៣

ដែលបានចាប់ផ្តើមឲ្យមានក្រុមជំនុំដំណឹងល្អ សព្វថ្ងៃនេះនៅក្នុងប្រទេសកម្ពុជាយើង ។

ការងារចាប់ផ្តើមដំបូង នៅក្នុងខេត្តបាត់ដំបង ដែលនៅក្នុងចំណោមបងប្អូនមកពីកម្ពុជាក្រោម ដែលបង្ហាញនូវការព្រមឆ្លើយតបចំពោះដំណឹងល្អបានយ៉ាងល្អ ។ ក្រុមដែលគេបានស្គាល់មុនគេ គឺនៅក្នុងភូមិ ឆ្កែកូន ដែលលោកយាយ យឹម នៅរស់នៅឡើយ គាត់បានមករស់នៅទីនោះ កាលគាត់អាយុ ៥ ឆ្នាំ និង គាត់បានផ្សាយដំណឹងល្អពីព្រះជាម្ចាស់នៅក្នុងប្រទេសកម្ពុជា ជាមួយនឹងឪពុកម្តាយរបស់គាត់ ។

ឥឡូវនេះ នៅក្នុងសតវត្សរ៍ក្រោយនេះ តើក្រុមជំនុំនៅឯណា? ចម្លើយមួយយ៉ាងងាយនោះគឺ នៅគ្រប់ទីកន្លែងទាំងអស់! ពីព្រោះនេះគឺជាលើកដំបូងហើយ ដែលយើងអាចប្រទះឃើញមានក្រុមគ្រីស្តបរិស័ទនៅគ្រប់ខេត្តនៅទូទាំងប្រទេស ។ នៅពេលដែលលោកអ្នកគិតពិចារណាពីភាពវឹកវរនៃប្រវត្តិសាស្ត្រប្រទេសនេះ គឺជាការអស្ចារ្យណាស់ ដែលយើងឃើញថាព្រះជាម្ចាស់បានធ្វើការ ដោយហេតុនោះទើបមានមនុស្សអាចទទួលជឿ និង ជឿពិតប្រាកដនៅក្នុងព្រះគ្រីស្ទ ។ ក្នុងរយៈកាលជាងម្ភៃឆ្នាំ មានការប៉ុនប៉ងលុបបំបាត់ជំនឿគ្រីស្តបរិស័ទ (ដែលគេចាត់ទុកថាជាសាសនាបែបលោកខាងលិច និង ជាសាសនារបស់ពួកចក្រពត្តិ) ការលុបបំបាត់គ្រប់សាសនាទាំងអស់ ។ តែទោះជាយ៉ាងណាក៏ដោយព្រះជាម្ចាស់រក្សាទុកឲ្យមាននៅសល់ អ្នករួចពីស្លាប់មួយចំនួន ដែលបានប្រកាន់ខ្ជាប់ចំពោះជំនឿរបស់ខ្លួន ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ ។ នៅក្នុងគម្ពីរអេសាយ ៤៦:៣-៤ ដែលបានចែងថា "ចូរស្តាប់ យើង! . . . អ្នកទាំងអស់គ្នាជាពូជពង្សអ៊ីស្រាអែល ដែលនៅសល់ . . . តាំងពីអ្នករាល់គ្នានៅក្នុងផ្ទៃម្តាយ យើងបានបីបាច់ថែរក្សាអ្នករាល់គ្នា . . . យើងនៅតែជួយគាំទ្រអ្នករាល់គ្នា . . . និង រំដោះអ្នករាល់គ្នា ។

## ការដឹកនាំ

នៅក្នុងឆ្នាំ ១៩៧៤ មានគ្រូគង្វាលពេញពេលតែ ១២ នាក់ប៉ុណ្ណោះ ទោះបីជាមានមនុស្សជាច្រើនបានទទួលនូវការហ្វឹកហ្វឺន នៅក្នុងសាលាព្រះគម្ពីរ តាខ្មៅ ក៏ដោយ ។ សិស្សទាំងអស់ដែលខ្ញុំបានបង្រៀននៅទីនេះកាលពីឆ្នាំ ១៩៧៤-៧៥ បានវិនាសបាត់បង់សូន្យសុង ក្នុងអំឡុងពេលខ្មែរក្រហមកាន់អំណាច ក្រៅពីនោះមានម្នាក់ឈ្មោះ ញែម សុគន្ធ ដែលបានស្លាប់ក្រោយពេលទៅដល់សហរដ្ឋអាមេរិកមិនយូរប៉ុន្មាន ។ តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលខ្ញុំសម្លឹងមើលជុំវិញនៅសព្វថ្ងៃនេះ ខ្ញុំឃើញថាមានអ្នកដឹកនាំក្រុមជំនុំតិចតួចណាស់ ដែលជាគ្រីស្ទបរិស័ទកាលពីមុនឆ្នាំ ១៩៧៥ តាមពិតទៅដោយសារព្រះគុណព្រះជាម្ចាស់ដែលបានរក្សាទុកអ្នកទាំងនោះ ឲ្យនៅសល់ពីគ្រោះអាក្រក់នោះ តែផ្ទុយទៅវិញមនុស្សភាគច្រើន ដែលកំពុងតែមាននាទីជាអ្នកដឹកនាំ នៅក្នុងពេលបច្ចុប្បន្ននេះ បានទទួលជឿព្រះនៅក្រោយឆ្នាំ ១៩៩០ ។ នេះគឺជាការពិតស្ទើរតែចាស់ទុំជំនួយ និង គ្រូគង្វាលនៅក្នុងក្រុមជំនុំជាច្រើននៅក្នុងប្រទេសគឺបែបហ្នឹងឯង ។ ហេតុដូច្នេះហើយ គេមានគំរូតិចតួចណាស់ដើម្បីដើរតាមហេតុការណ៍ ដែលបង្ហាញឲ្យឃើញថា របៀបដែលគេរៀបចំចាត់ចែងក្រុមជំនុំរបស់គេ ដូចជាសមាគម ឬ ជាក្រុមសង្គមមនុស្សរស់នៅជាមួយគ្នា ដោយមានការជ្រើសរើសគណៈកម្មាធិការក្រុមមួយចំនួនមានការតែងតាំងឲ្យមានអ្នកអ្នកដឹកនាំ ដោយសារតែគេមានគុណសម្បត្តិផ្នែកវិញ្ញាណសមស្របទៅនឹងគំរូរបស់សេចក្ដីបង្រៀនរបស់លោកប៉ូល។

## ការហ្វឹកហ្វឺនអ្នកដឹកនាំ

នៅពេលដែលក្រុមជំនុំចាប់ផ្ដើម កើនឡើងកាន់តែច្រើន ការស្រែកដង្ហោយហៅបានលេចធ្លោឡើង "យើងត្រូវការការហ្វឹកហ្វឺនអ្នកដឹកនាំ!" បេសកកម្មគ្រីស្ទបរិស័ទជាច្រើនក្រុម បានឆ្លើយតបទៅនឹងការ

ស្រែកដង្ហោយហៅនេះ ដែលបង្កើតជាសិក្ខាសាលាជាច្រើន សាលាព្រះគម្ពីររយៈពេលខ្លី និង វគ្គហ្វឹកហ្វឺនដែលបានចុះនៅលើប្រតិទិនស្ទើរតែរៀងរាល់ខែ ។ កម្មវិធីអប់រំផ្នែកទេវសាស្ត្រ ដែលពង្រីកឲ្យទូលំទូលាយ (TEE) ដែលបង្កើតឡើងដោយសារនិកាយ សម្ព័ន្ធបេសកកម្មសាសនទូតគ្រីស្តបរិស័ទដំណឹងល្អ(C & MA) នៅពេលបច្ចុប្បន្ននេះមានមនុស្ស ៦០០ នាក់បានទទួលនូវការហ្វឹកហ្វឺនតាមកម្មវិធីនេះ ដែលភាគច្រើននៅតាមបណ្តាខេត្ត ។ មេរៀនទាំងឡាយ ដែលគេបានសរសេរពីដើមសំរាប់អ្នកដឹកនាំក្រុមជំនុំនៅក្នុងទ្វីបអាហ្វ្រិកខាងត្បូង ។រួចក្រោយមកគេបានបកប្រែយ៉ាងល្អ និង ស៊ីនឹងស្ថានភាពអ្នកដឹកនាំខ្មែរល្អឥតទាស់ ។ គេបានបង្កើតសមាគម TEE ឡើងដើម្បីធ្វើឲ្យកម្មវិធីហ្វឹកហ្វឺននេះយោងទៅដល់ក្រុមជំនុំទាំងអស់ទូទាំងកម្ពុជា ។ មានកម្មវិធីហ្វឹកហ្វឺនបែប TEE មួយទៀត ដែលពួកជំនុំព្រះជាម្ចាស់ "Assemblies of God" បានបង្កើតឡើង ឲ្យឈ្មោះថា "ហ្វឹកហ្វឺន និង ធ្វើជាពហុគុណ" ។ ការនេះផ្តោកទៅលើការដាក់កំណត់ដោយផ្ទាល់ខ្លួនរបស់អ្នកដឹកនាំ ដែលត្រូវបន្តទៅត្រួតមើលការផ្តល់គំនិតដល់អ្នកដទៃទៀត តាមពិតទៅជាដំណឹងល្អ! ។

មានវគ្គសិក្សា ដែលទៅដល់កន្លែងអ្នករៀន គឺរៀបចំឡើងដោយមជ្ឈមណ្ឌលហ្វឹកហ្វឺនទាំង ៧ កន្លែងរបស់ក្រុមជំនុំ បាប់ទីស្ទ នៅក្នុងទូទាំងប្រទេស ដែលមានរយៈពេលរៀនម្តង ២ អាទិត្យ ។ បន្ទាប់ពី ២ ឆ្នាំក្រោយមកអ្នកដឹកនាំក្រុមជំនុំនៅតាមជនបទ នឹងសិក្សាបាន ៨ វគ្គ ដែលបានផ្តល់នូវការហ្វឹកហ្វឺនជាមូលដ្ឋាន នៅក្នុងផ្នែកដឹកនាំក្រុមជំនុំ និង ការបង្រៀនព្រះគម្ពីរ ។ សាលាព្រះគម្ពីរភ្នំពេញ មានសិស្ស ៦ ជំនាន់ហើយបានប្រឡងចេញពីសាលានេះ ដែលសិស្សទាំងនោះបានចំណាយពេលសិក្សាអស់រយៈពេល បី ឆ្នាំ និងការចុះឈ្មោះចូលរៀនលើកនេះ គឺត្រូវរៀនរយៈពេល ៦ ឆ្នាំ ។ អង្គការនិស្សិតថ្វាយព្រះគ្រីស្ត បានរៀបចំសាលាហ្វឹកហ្វឺនអ្នកផ្សាយដំណឹងល្អ ហើយក្រុមជំនុំព្រះជាម្ចាស់បានបើកសាលា

ព្រះគម្ពីររបស់ខ្លួន នៅក្នុងខែ កក្កដា ឆ្នាំ ១៩៩៦ ។ អង្គការកម្ពុជាថ្វាយព្រះគ្រីស្ទ ក៏មានវគ្គហ្វឹកហ្វឺនទៅដល់កន្លែងសិស្សរស់នៅផងដែរ មេតូឌីសក៏មានដូចគ្នាដែរ ។ មានវគ្គសិក្សាខ្លីៗជាច្រើន ដែលគេបានរៀបចំឡើងផងដែរ នៅក្នុងក្រុងភ្នំពេញ និង នៅតាមខេត្ត ដែលមានអ្នកដឹកនាំក្រុមជំនុំមកពីកន្លែងផ្សេងៗ នៅក្នុងប្រទេសមកចូលរួម ។

សម្ភារៈសំរាប់ការហ្វឹកហ្វឺន មានមកពីប្រភពជាច្រើនក្រៅពីសៀវភៅលំហាត់ ដែលសំរាប់រៀនជាមួយកម្មវិធី TEE និង វគ្គសិក្សានៃសាលាព្រះគម្ពីរ ដែលបានពោលខាងលើ ។ សៀវភៅមួយឈ្មោះ Leroy Eims' How to be a Leader បានបកប្រែពីភាសាថៃ និង បានរៀបចំចងក្រង នៅឆ្នាំ ១៩៩២ ។ មានទំហំធំធេងណាស់ចំពោះសៀវភៅគ្រីស្ទបរិស័ទ និង សៀវភៅ ផ្នែកផ្សាយដំណឹងល្អ ដែលត្រូវការឲ្យគេបង្កើតឡើង សំរាប់ជួយដល់ក្រុមជំនុំក្នុងស្រុក ប្រយោជន៍ឲ្យគេអាចអាន ដើម្បីបង្កើនជំនឿដោយខ្លួនគេផ្ទាល់ ប៉ុន្តែមានមនុស្សតិចតួចណាស់ដែរ ដែលមានឱកាសរកបានសៀវភៅទាំងនេះ ឬ ក៏អាចទិញសៀវភៅទាំងនេះយកទៅអានបាន ។ មានមនុស្សតិចតួចណាស់ដែរ ដែលមានវិទ្យុដែលអាចចាប់បានរលកធាតុអាកាសករិតខ្លី ដែលជាប្រភពនៃការបង្រៀនយ៉ាងសម្បើមមួយផ្សេងទៀត គឺតាមរយៈការផ្សាយជាប្រចាំថ្ងៃ របស់វិទ្យុសម្លេងនៃសេចក្ដីស្រឡាញ់ FEBC ទោះបីយ៉ាងណាក៏ដោយ អស់អ្នកដែលរស់នៅជិតនឹងស្ថានីយ៍ FM មានការជ្រើសរើសក្នុងការបើកស្ដាប់កម្មវិធីគ្រីស្ទបរិស័ទ ។ ខ្សែអាត់សម្លេង គេអាចស្ដាប់បានយ៉ាងច្រើនដងដោយប្រើម៉ាញ៉េ និង មានអ្នកខ្លះគេប្រើការចែកចាយសម្ភារៈបង្រៀនតាមបែបនេះ ។ ប៉ុន្តែមានការប្រើច្រើនទៀត ដែលគេអាចប្រើបានចំពោះសម្ភារៈ ដែលគេបានរៀបចំហើយនោះ បើសិនជាមានបណ្ណាល័យមួយដែលគេរៀបចំឡើងនៅតាមមជ្ឈមណ្ឌលគ្រីស្ទបរិស័ទនានា ។

## ការផ្សាយដំណឹងល្អ

គ្រីស្តបរិស័ទខ្មែរភាគច្រើនជឿព្រះតាមរយៈការធ្វើបន្ទាល់ពីគ្រួសារ ឬមិត្តភក្តិជិតស្និទ្ធ ។ គេមិនគ្រាន់តែបានឮដំណឹងល្អពីសាច់ញាតិគ្រួសារ មិត្តភក្តិប៉ុណ្ណោះទេ គឺគេបានឃើញនូវព្រះចេស្តានៃដំណឹងល្អនោះបំផ្លាស់បំប្រែជីវិតរបស់គេទៀតផង ។ ជួនកាលសាច់ញាតិរបស់គេដែលរស់នៅឯបរទេស ដែលបានទទួលជឿព្រះកាលនៅក្នុងជំរំជនភៀសខ្លួន ឬ ពេលទៅដល់ប្រទេសទីបីនោះ បានមកលេងស្រុករួចពន្យល់ប្រាប់ពីដំណឹងល្អដល់ពួកគេ ។

ប៉ុន្តែមានករណីខ្លះ ដោយមានចិត្តសប្បុរសយ៉ាងកក់ក្តៅ តាមរយៈគ្រីស្តបរិស័ទនៅឯក្រៅប្រទេស ដែលនាំឲ្យមានការស្រពិចស្រពិល យល់មិនច្បាស់ ដែលជាហេតុនាំឲ្យសាច់ញាតិក្រក្រី គិតថាការក្លាយជាគ្រីស្តបរិស័ទនោះ គឺជាផ្នែកមួយនៃការតថ្លៃសុំជំនួយទៅវិញ ។ អ្នកជឿថ្មីភាគច្រើនតែងតែសួរថា តើគេទទួលបានប្រាក់ខែប៉ុន្មាន ក្នុងការដែលគេក្លាយជាគ្រីស្តបរិស័ទនោះ មិនមែនជាការងាយស្រួលក្នុងការឆ្លើយនូវចម្លើយដ៏សមរម្យដល់គេឡើយ ដើម្បីលុបបំបាត់គំនិតខុសឆ្គងបែបនេះ ។

អ្នកខ្លះក្លាយជាគ្រីស្តបរិស័ទ ដោយសារព្រះជាម្ចាស់ប្រោសគេឲ្យជា ។ ជម្ងឺកើតឡើងជាច្រើន ហើយជារឿងសាមញ្ញទៅហើយ និង ទម្លាប់ទៅរកគ្រូបុរាណ (គ្រូខ្មែរ) នោះគឺនៅតែពេញនិយមនៅឡើយ ។ នៅក្នុងស្ថានការណ៍បែបនេះ ព្រះជាម្ចាស់បានចូលមកហើយ បង្ហាញនូវព្រះចេស្តារបស់ព្រះអង្គ ប្រោសឲ្យគេជាទាំងជម្ងឺរូបកាយ និង ជម្ងឺផ្លូវចិត្ត ព្រមទាំងដោះលែងមនុស្សជាច្រើន ដែលបានអនុញ្ញាតឲ្យអារក្សធ្វើទុក្ខ ឬ ឲ្យវាប្រើជាអ្នកចូលរូបនោះ ឲ្យរួចពីអំណាចទាំងនោះផងដែរ ។ អស់អ្នកដែលបានជាទាំងនោះឯង បានប្រកាសប្រាប់ពីព្រះរាជសារនៃសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ ដែលខ្ពស់ហួសពីការយល់ដឹង មិនដែលធ្លាប់ស្គាល់ពីមុនមក គឺមុនពេលដែលគេទទួលជឿព្រះគ្រីស្ទ ។

បែបផែននៃការផ្សាយដំណឹងល្អ ដែលប្រកបដោយអំណាចចេស្ដាបំផុតនោះ គឺការបំផ្លាស់បំប្រែជីវិត ដោយសារអំណាចចេស្ដារបស់ព្រះគ្រីស្ទ ។ នៅក្នុងសហគមន៍តាមជនបទគ្មាននរណាម្នាក់អាចលាក់ខ្លួនបានឡើយ និង មិនយូរប៉ុន្មានបានឮការជជែកគ្នារបស់អ្នកភូមិ នៅពេលដែលជីវិតរបស់អ្នកណាម្នាក់មានការផ្លាស់ប្រែយ៉ាងប្លែកអស្ចារ្យនោះ ។ នៅក្នុងពេលថ្មីៗនេះ ខ្ញុំបាននិយាយជាមួយអតីតទាហានម្នាក់ នៅក្នុងខេត្តស្វាយរៀង ដែលបានបញ្ជាក់ឲ្យដឹងថា គាត់មានមេរោគ HIV នៅក្នុងឈាមដោយសារតែជីវិតរស់នៅរបស់គាត់ ពីមុនមានការប្រព្រឹត្តិមិនសូវល្អ ហើយគាត់បានចំណាយរាប់រយដុល្លារដើម្បីព្យាបាល ។ គាត់មានការទាក់ចិត្ត ចំពោះដំណឹងល្អ ដោយសារតែឥរិយាបថនៃ "ការទុកចិត្តព្រះគ្រីស្ទ" របស់អ្នកភូមិ ដែលរស់នៅជាមួយគាត់ខ្លះ ។ ឥឡូវនេះគាត់កំពុងដើរតាមព្រះគ្រីស្ទ ដែលព្រះអង្គពិតជាឆក់លើកឡើងឲ្យរួចពីភ្លើង(យូដាស ២៣) ។

## ការថ្វាយបង្គំ

ស្ទើរតែជារៀងរាល់ថ្ងៃអាទិត្យ ក្នុងប្រទេសកម្ពុជាមានក្រុមគ្រីស្ទបរិស័ទជួបប្រជុំគ្នាជាលើកដំបូង ដើម្បីថ្វាយបង្គំព្រះ ដែលជាព្រះដ៏ពិត និង ជាព្រះដ៏មានព្រះជន្មរស់ ។ រៀងរាល់ឆ្នាំមានគ្រីស្ទបរិស័ទជាច្រើនរយនាក់ រៀបចំធ្វើពិធីបុណ្យព្រះអង្គមានព្រះជន្មរស់ និង បុណ្យណូអែលជាលើកទី ១ របស់ខ្លួន ។ ក្រុមជំនុំរបស់ព្រះ បន្តរីកចំរើនលូតលាស់យ៉ាងច្រើន ប៉ុន្តែគឺនៅតែត្រូវការបំប៉នឲ្យចម្រើនវ័យ ដើម្បីសម្រេចដល់ពេញខ្នាតមួយ ដែលព្រះគ្រីស្ទ បានរៀបចំសំរាប់រូបកាយរបស់ព្រះអង្គ ។ ព្រះរាជបំណងរបស់ព្រះអង្គគឺ ត្រូវនាំឲ្យក្រុមជំនុំឲ្យមានការឯកភាពរបស់ព្រះវិញ្ញាណ ។ ពីមួយឆ្នាំទៅមួយឆ្នាំ យើងឃើញមានចលនាមួយកំពុងរំកិលចំទិសដៅ ឆ្ពោះទៅរកការទទួលស្គាល់នូវភាពជាព្រះសិរសាររបស់ព្រះគ្រីស្ទ ។ តែគួរឲ្យសោកស្ដាយណាស់ ដែលនៅតែមានអ្នកដែលកំពុងខំ

បង្កើតក្រុម ឬ និកាយរបស់ពួកគេ ដោយមិនបានជំរុញឲ្យមានការប្រកបជិតស្និទ្ធ និង ជួយពង្រឹងគ្នាទៅវិញទៅមកនៅនឹងកន្លែងមួយ ដែលគេនៅជាមួយគ្នានោះ ។ ប៉ុន្តែនឹងដល់ពេលមួយ ដែលគេនៅជាមួយគ្នានោះ ។ ប៉ុន្តែនឹងដល់ពេលមួយដែលគ្រីស្ទបរិស័ទនៅក្នុងស្រុក នឹងទទួចចង់បាននូវសេចក្តីពិត ដែលពួកគេជា "រូបកាយទាំងមូល បានផ្គុំគ្នា និង ភ្ជាប់គ្នាឡើងយ៉ាងមាំ ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មាន ដែលបំរើព្រះកាយ តាមកំរិតសមត្ថភាពរបស់សរីរាង្គនីមួយៗ ដើម្បីឲ្យព្រះកាយនោះចំរើន និង កសាងឡើងក្នុងសេចក្តីស្រឡាញ់ (អេភេសូ ៤:១៦)" ។

នេះគឺជាការពិតរួចហើយ ក្នុងបទពិសោធន៍នៃការថ្វាយបង្គំ ដែលគ្រីស្ទបរិស័ទខ្មែរ មានបទចំរៀងសរសើរព្រះរបស់ខ្លួនឯងផ្ទាល់ ហើយច្រៀងដោយមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលជាចម្រៀង ដែលតែងដោយខ្លួនឯង ដែលព្រះអម្ចាស់ព្រះអង្គបានប្រទានឲ្យ ។ នេះជាអំណោយទានដ៏ពិសេសនៃតន្ត្រី និង កំណាព្យកាព្យឃ្លោង និង បែបផែនផ្នែកសិល្បៈ ដែលជាមត៌ករបស់ប្រជារាស្ត្រខ្មែរ ហើយឥឡូវនេះខ្មែរយកមកប្រើដើម្បីថ្វាយបង្គំព្រះ តើមិនអស្ចារ្យទេអី! មានមន្ត្រីម្នាក់ធ្វើការនៅក្នុងក្រសួងធម្មការ និង វប្បធម៌នៅខេត្តកំពង់ធំ នៅពេលថ្មីៗនេះបានសម្តែងនូវការកោតសរសើរដល់ក្រុមជំនុំនៅទីនោះ ដោយព្រោះបានលើកស្ទួយដល់វប្បធម៌ខ្មែរ តាមរយៈបទចំរៀងថ្វាយបង្គំព្រះរបស់ពួកគេ ។

## ការអភិវឌ្ឍន៍នៅថ្ងៃអនាគត

ការដែលបានសម្លឹងមើលនូវការលូតលាស់ដ៏គួរសុំគួរសាល របស់ក្រុមជំនុំក្នុងរយៈពេលជាង ១០ ឆ្នាំកន្លងមកនេះ ខ្ញុំសង្ឃឹមថា ការលូតលាស់នេះ គឺបន្តទៅទៀត រហូតដល់មានភូមិជាច្រើនទៀតបានទទួលនូវដំណឹងល្អ ។ សព្វថ្ងៃនេះមនុស្សជាច្រើន ដែលពីមុនធ្លាប់ប្រឆាំងមិនព្រមទទួលដំណឹងល្អបានក្លាយជាអ្នកគ្រីស្ទបរិស័ទ គឺដូចគ្នាកាលពីជំនាន់ដើម

ដែលបេសកជនផ្សាយដំណឹងល្អទៅ មានមនុស្សជាច្រើនបានឮមែន តែមានតិចតួច ដែលបានទទួលជឿដល់ព្រះ ។ យើងត្រូវតែឈោងចាប់ទៅដល់អ្នក ដែលមិនដែលមានឱកាស ទទួលដំណឹងល្អជាបន្តទៀត ។

នៅក្នុងនាមជាគ្រីស្ទបរិស័ទ ដែលចាស់ចិត្តចាស់គំនិត គេត្រូវតែមានបន្ទុកក្នុងចិត្ត ក្នុងការគិតនាំយកដំណឹងល្អ ទៅដល់ភូមិស្រុកដទៃទៀត ដែលនៅខេត្តរបស់ខ្លួនផ្ទាល់ និង ទៅខេត្តផ្សេងពីនោះទៀតផង ។ កាន់តែចំរើនវ័យផ្នែកជំនឿនឹងកាន់ឲ្យមានការទទួលខុសត្រូវក្នុងការ "ចិញ្ចឹមបីបាច់ថែរក្សា" និង ប្រដៅតម្រង់ដល់គ្រីស្ទបរិស័ទ ដែលទើបនឹងជឿថ្មីៗ ។ នៅពេលបច្ចុប្បន្ននេះ មានអ្នកជឿថ្មីជាច្រើន នៅតែឯងដោយខ្វះការថែបំប៉នជំនឿគ្រប់គ្រាន់ ។ ខ្ញុំមានសង្ឃឹមថា ក្រុមជំនុំនឹងរីកចំរើនឡើងជាពិតប្រាកដ ទៅជាសហគមន៍គ្រីស្ទបរិស័ទ ដែលចេះយកអាសាគ្នា រាប់ទុកដូចជាគ្រួសាររបស់ខ្លួនគេផ្ទាល់ និង ព្រមទាំងចេះស្វាគមន៍ដល់អ្នកទើបនឹងជឿថ្មី ដោយរាប់ទុកគេជាផ្នែកមួយនៅក្នុងគ្រួសារនេះ ។

នៅពេលបច្ចុប្បន្ននេះ ក្រុមជំនុំ និង និកាយជាច្រើន កំពុងពឹងផ្អែកយ៉ាងខ្លាំងលើជំនួយពីបរទេស និងពីអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ហេតុដូច្នេះហើយគេមិនបានមើលឃើញច្បាស់ពីការទទួលខុសត្រូវ របស់គេផ្ទាល់ដើម្បីធ្វើតាមព្រះរាជបង្គាប់របស់ព្រះគ្រីស្ទឲ្យចេញទៅផ្សាយដំណឹងល្អ ដែលព្រះជាម្ចាស់បានផ្ដល់ឲ្យមកនោះឡើយ ។ ជនបរទេសទាំងឡាយអើយ ចូរធ្វើការវាយតម្លៃថា តើជំនួយរបស់ខ្លួន គឺពិតជាពង្រឹងដល់ជំនឿអ្នកជឿថ្មី ឲ្យគេជឿដល់ព្រះជាម្ចាស់ ដែលព្រះអង្គ "នឹងផ្ដល់ឲ្យ" នូវអ្វីដែលគេត្រូវការមែន ឬ ក៏យើងពិតជាបែរទៅជាការរា រាំងជាជាងការដែលជួសការទុកចិត្តឲ្យគេទុកចិត្តព្រះជាម្ចាស់ ដោយធ្វើឲ្យក្លាយជាអ្នកដែលឲ្យគេទុកចិត្តជំនួយព្រះជាម្ចាស់ទៅវិញ ។

ក្នុងនាមជាគ្រីស្ទបរិស័ទ មានការរីកចំរើន គេនឹងស្គាល់ព្រះជាម្ចាស់កាន់តែជ្រាលជ្រៅមួយកំរិតទៀត និង បានទទួលស្គាល់ព្រះអង្គទុក

ជាចំណែកសំខាន់នៅក្នុងជីវិតរបស់គេ គ្រួសាររបស់គេ និង ក្រុមជំនុំរបស់គេ ។ សព្វថ្ងៃនេះយើងមានក្រុមជំនុំចំរុះក្រុមជំនុំជាច្រើន ដែលជាញយៗតែងតែប្រជែងគ្នា (ដូចជាការតាំងហាងលក់ឥវ៉ាន់ជាមួយគ្នា ដើម្បីទាក់ទាញអតិថិជនដូច្នេះដែរ) ។ នៅពេលដែលផ្តោតយកព្រះជាម្ចាស់ទុកជារឿងសំខាន់ ។ បន្ទាប់មកភាពខុសគ្នានឹងថយចុះ ពេលនោះគ្រីស្តបរិស័ទព្រមចូលរួមប្រកបជាមួយគ្នា គឺផ្តល់ឲ្យមានឥទ្ធិពលផងដែរលើមនុស្ស ៩៩.៥% ដែលរស់នៅក្នុងប្រទេសកម្ពុជា មិនទាន់ទទួលស្គាល់ព្រះគ្រីស្តជាព្រះអង្គសង្គ្រោះនៅឡើយនោះ ។

"សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ នៅស្ថានដ៏ខ្ពស់បំផុតហើយ សូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្តីសុខសាន្ត នៅលើផែនដី ! " (លូកា ២:១៤) ។